ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
**អគ្គនាយកដ្ឋានរដ្ឋបាល**
**នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល**
លេខ.០៥១...............ន.ប.ប.

ថ្ងៃពុធ ២ កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩

**សូមគោរពជូន**
- **ឯកឧត្តមអគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋាន ប.ព.គ.**
- **ឯកឧត្តមប្រធានវិទ្យាស្ថានជាតិ ប.ទ.ប.ព.គ.**
- **ឯកឧត្តមប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា**
- **លោកប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**
- **លោក លោកស្រីប្រធានមន្ទីរប.ទ.**

**កម្មវត្ថុ** : ស្តីពីការផ្សព្វផ្សាយកម្មវិធីអាហារូបករណ៍ថ្នាក់អនុបណ្ឌិតឆ្នាំសិក្សា២០១៩ នៅសាធារណៈរដ្ឋកូរ៉េ។

**យោង** : លិខិត KOICA-Cambodia-2019-248 ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោក លោកស្រី ប្រធាន** មេត្តាជ្រាបថា ភ្នាក់ងារសហប្រតិបត្តិការកូរ៉េ (Korea International Cooperation Agency) ប្រចាំនៅប្រទេសកម្ពុជា បានធ្វើការផ្សព្វផ្សាយអាហារូបករណ៍ថ្នាក់អនុបណ្ឌិតដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល សូមធ្វើការផ្សព្វផ្សាយថ្នាក់អាហារូបករណ៍ដល់គ្រប់អង្គភាពក្រោមឱវាទក្រសួងប.ទ.ដើម្បីជូនជ្រាបដល់មន្ត្រីរាជការដែលមានចំណាប់អារម្មណ៍ ហើយនិងត្រូវតាមលក្ខខណ្ឌក្នុងការទទួលអាហារូបករណ៍ខាងលើនេះ (ដូចមានឯកសារព័ត៌មានលម្អិត និងឈ្មោះវគ្គនីមួយៗ ភ្ជាប់ជូន)។ សម្រាប់ព័ត៌មានបន្ថែមចំពោះអាហារូបករណ៍ខាងលើ សូមចូលទៅកាន់គេហទំព័រ http://www.koicacambodia.org/scholar-ship-program-for-2019/ or Email: koicascholar@gmail.com។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោក លោកស្រី ប្រធាន** មេត្តាជ្រាប និងជួយផ្សព្វផ្សាយអាហារូបករណ៍ខាងលើជូនដល់មន្ត្រីក្រោមឱវាទដែលចាប់អារម្មណ៍អាហារូបករណ៍ខាងលើ និងសូមអនុញ្ញាតឱ្យមន្ត្រីទាំងនោះបំពេញបែបបទអាហារូបករណ៍ (Application Form) រួចបញ្ជូនមកនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល ឱ្យបានមុនថ្ងៃ**ទី០៤ ខែមីនា ឆ្នាំ២០១៩** ដើម្បីឱ្យនាយកដ្ឋាន រៀបចំបែបបទលិខិតផ្លូវការទាន់ពេលវេលា។

សូម **ឯកឧត្តម លោក លោកស្រី ប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធាននាយកដ្ឋាន**

ជួន ដារ៉ូ

**ព័ត៌មានបន្ថែម៖**
*សូមទំនាក់ទំនងការិយាល័យបណ្តុះបណ្តាល៖
ទូរស័ព្ទលេខ: -០៧៨ ៦៧៨ ៩៥០
-០៩៦ ៧០០ ៦៦៦៦